# នៅគ្រប់ពេល និងគ្រប់សេចក្តី និងគ្រប់ទីកន្លែង

ស៊ីស្ទើរ អេលែន អេស ដាល់ថុន
ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានយុវនារីទូទៅ

*នៅពេលដែលអ្នកឈរជាសាក្សី គោរពតាមព្រះបញ្ញត្តិទាំងឡាយ ហើយឈានទៅមុខដោយ "ខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ" នោះអ្នកនឹងមិននៅតែម្នាក់ឯងឡើយ ។*

នេះគឺជាកិត្តិយសណាស់ដើម្បីឈរនៅចំពោះអ្នករាល់គ្នា ហើយថ្លែងទីបន្ទាល់អំពីព្រះអង្គសង្គ្រោះ និងជីវិតដែលមិនអាចប្រៀបផ្ទឹមរបស់ទ្រង់។ ទ្រង់បានយាងមកផែនដីដើម្បីបង្ហាញដល់យើងនូវរបៀបដើម្បីរស់នៅតាមផែនការដែលត្រូវបានតែងឡើងនៅឋានសួគ៌--- ជាផែនការមួយដែលនឹងធ្វើឱ្យយើងបានសប្បាយរីករាយ បើយើងរស់នៅតាម។ គំរូរបស់ទ្រង់បានបង្ហាញដល់យើងនូវផ្លូវដើម្បីត្រឡប់ទៅកាន់ផ្ទះ និងព្រះវរបិតាសួគ៌របស់យើងវិញ។ គ្មាននរណាផ្សេងទៀតដែលធ្លាប់រស់នៅ "យ៉ាងខ្ជាប់ខ្ជួន ហើយឥតបែរចេញ" នោះទេ (ម៉ូសាយ 5:15)។ ទ្រង់មិនដែលបែរចេញទេ។ ទ្រង់ផ្តោតព្រះទ័យទុកដាក់ទៅលើការអនុវត្តតាមព្រះរាជបំណងរបស់ព្រះបិតា ហើយទ្រង់នៅតែពិតចំពោះបេសកកម្មដ៏ទេវភាពរបស់ទ្រង់។ ប្រាកដណាស់ យើងអាចនិយាយអំពីទ្រង់ថា ទ្រង់ពិតនៅគ្រប់ពេល និងគ្រប់សេចក្តី និងគ្រប់ទីកន្លែង។ (សូមមើលម៉ូសាយ 18:9)។

អ្នកមានចំណែកនៅក្នុងផែនការដ៏មហិមានោះ ដែលត្រូវបានបង្ហាញឡើងនៅក្នុងអាណាចក្រជីវិតមុនចាប់កំណើត។ ការមកកាន់ផែនដីរបស់អ្នកក្នុងពេលឥឡូវនេះ ត្រូវបានចូលរួមចំណែក ចាប់តាំងពីផែនការត្រូវបានទទួលយកមកម្ល៉េះ។ ទីតាំងរបស់អ្នកនៅក្នុងពេលវេលា និងទីកន្លែងនេះមិនមែនដោយដៃចន្យនោះទេ។ "សេចក្តីជំនឿដ៏លើសលប់ និងកិច្ចការដ៏ល្អទាំងឡាយ" របស់អ្នក (អាលម៉ា 13:3 ) ពេលនោះបានចាក់គ្រឹះសំរាប់អ្វីដែលអ្នកអាចសម្រេច នៅពេលឥឡូវនេះ បើអ្នកស្មោះត្រង់ និងគោរពប្រណិបត្តិ។ អ្នកគឺជាបុត្រីដ៏មានតម្លៃរបស់ព្រះ ហើយអ្នកមានកិច្ចការដ៏មហិមាមួយដើម្បីធ្វើ។ ដើម្បីសម្រេចនូវបេសកកម្មដ៏ទេវភាពរបស់អ្នក និងរស់នៅតាមផែនការនៃសុភមង្គល អ្នកក៏ត្រូវតែនៅខ្ជាប់ខ្ជួន ហើយនឹងនឹងនរ "នៅគ្រប់ពេល និងគ្រប់សេចក្តី និងគ្រប់ទីកន្លែង" ផងដែរ (ម៉ូសាយ 18:9)។

អ្នកមានចំណែកមួយនៃផែនការដ៏មហិមា ដែលត្រូវបានបង្ហាញកាលពីនៅអណាចក្រមុនផែនដី។ ការយកផែនដីរបស់អ្នក ពេលឥឡូវនេះ ត្រូវបានរួមចំណែកតាំងពីផែនការត្រូវបានទទួលយកមកម្ល៉េះ។ ទីតាំងនៅក្នុងពេលវេលា និងទីកន្លែងរបស់អ្នកមិនមែនដោយដៃដន្យទេ។ "សេចក្តីជំនឿដ៏លើសលប់ និងកិច្ចការដ៏ល្អទាំងឡាយ" របស់អ្នក (អាលម៉ា 13:3) ពេលនោះបានចាក់គ្រឹះសំរាប់អ្វីដែលអ្នកអាចសម្រេចក្នុងពេលនេះ បើសិនជាអ្នកស្មោះត្រង់ និងគោរពប្រណិ-បត្តិ។ អ្នកគឺជាបុត្រីដ៏មានតម្លៃរបស់ព្រះ ហើយអ្នកមានកិច្ចការដ៏មហិមាមួយដើម្បីធ្វើ។ ដើម្បីសម្រេចនូវបេសកកម្មដ៏ទេវភាពរបស់អ្នក ហើយរស់នៅតាមផែនការនៃសុភមង្គល អ្នកត្រូវតែខ្ជាប់ខ្ជួន ហើយនឹងនរផងដែរ "នៅគ្រប់ពេល និងគ្រប់សេចក្តី និងគ្រប់ទីកន្លែង" (ម៉ូសាយ 18:9)។

អស់រយៈពេលជាច្រើនឆ្នាំកន្លងទៅ ខ្ញុំទទួលបានរូបថតអគារតូចៗចំនួនបី ដែលអគារពីរទ្រេតទៅលើអគារទីបី និងជាអគារដែលតូចជាងគេ។ ដោយមានចំណងជើងសរសេរថា: "អ្នកចាំបាច់ត្រូវតែរឹងមាំ នៅពេលអ្នកគឺជាមនុស្សចុង

ក្រោយគេដែលត្រូវតទល់"។ អ្នកទាំងអស់គ្នាក៏ត្រូវរឹងមាំផងដែរ។ នៅពេលអ្នកស្មោះត្រង់ និងសុចរិត អ្នកដទៃនឹងសង្ឃឹមទៅលើអ្នកនូវការគាំទ្រ និងកម្លាំង។

ហេលេមិនពិពណ៌នាអំពីរបៀបដែលការណ៍ទាំងនេះអាចកើតឡើងថា "ហើយឥឡូវនេះ ចូរចងចាំចុះ...ចងចាំចុះថាគឺនៅលើសិលានៃព្រះដ៏ប្រោសលោះនៃយើង គឺព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ដែលកូនត្រូវសង់គ្រឹះរបស់កូន... ដែលជាគ្រឹះដ៏ខ្ជាប់ខ្ជួនមួយ ជាគ្រឹះមួយបើសិនណាមនុស្សសង់នៅលើនោះ នោះពួកគេមិនអាចរលំបានឡើយ" (ហេលេ-មិន 5:12)។

គ្រឹះនៃសេចក្ដីជំនឿរបស់អ្នក ត្រូវតែសង់យ៉ាងរឹងមាំទៅលើព្រះយេស៊ូវគ្រីស្ទ។ ការមានជំនឿប្រភេទនោះមានន័យថាអ្នកពឹងផ្អែកលើទ្រង់ អ្នកទុកចិត្តទៅលើទ្រង់ ហើយទោះបីជាអ្នកមិនយល់នូវអ្វីគ្រប់យ៉ាងក៏ដោយ អ្នកដឹងថាទ្រង់ជ្រាប។ អ្នកក៏ដឹងផងដែរថា អ្នកគឺជាបុត្ររបស់ព្រះ ថាទ្រង់ស្គាល់ឈ្មោះអ្នក ថាទ្រង់ស្ដាប់ការអធិស្ឋានរបស់អ្នក ហើយថាទ្រង់នឹងជួយអ្នកសំរេចនូវបេសកកម្មលើផែនដីរបស់អ្នក។

យុវជនម្នាក់ដែលខ្ញុំស្គាល់ច្បាស់ ត្រូវបានជ្រើសរើសឱ្យធ្វើជាប្រធាននិស្សិតក្នុងសាលានៅក្នុងសកលវិទ្យាល័យធំមួយ។ សកលវិទ្យាល័យបានបញ្ជូនគាត់ទៅសិក្ខាសាលាភាពជាអ្នកដឹកនាំមួយ ដែលមានពួកអ្នកដឹកនាំនិសិត្សមកពីចំរុះសហរដ្ឋបានប្រមូលផ្ដុំគ្នានៅក្នុងទីក្រុង ឈីកាហ្គូ រដ្ឋអិលលីណោយ ដើម្បីទទួលការបំពាក់បំប៉ន និងអប់រំ។ ពួកគេបានចូលរួមនៅក្នុងការចាប់ផ្ដើមលេងល្បែងកំសាន្តនៅខាងក្រៅក្នុងទីលាន សកលវិទ្យាល័យ ដើម្បីពួកគេអាចស្គាល់គ្នាទៅវិញទៅមក។ និសិត្សទាំងអស់ត្រូវឈរតំណាងឱ្យបញ្ហាថ្មីៗ ដែលយុវវ័យកំពុងតែប្រឈមមុខនៅពេលបច្ចុប្បន្ន ហើយត្រូវបានសុំឱ្យជ្រើសរើសក្រុម។ នៅក្នុងការឆ្លើយតបទៅនឹងបញ្ហាដែលឈរតំណាងឱ្យ ពួកគេត្រូវណែនាំឱ្យរត់ទៅកាន់ដើមឈើមួយចំនួនលើវាលស្មៅ ដែលគូសចំណាំថា "យល់ស្របយ៉ាងខ្លាំង" "យល់ស្របខ្លះៗ" "មិនយល់ស្របទេ" ឬ "មិនយល់ស្របពាក់កណ្ដាល"។ នៅចុងបញ្ចប់នៃល្បែងនេះ អ្នកដឹកនាំបានសួរថា "តើអ្នកជឿលើការរួមមេត្រីមុនពេលរៀបការឬទេ? ដោយគ្មានស្ទាក់ស្ទើរ យុវជនម្នាក់នេះបានរត់ទៅដើមឈើដែលគូសចំណាំថា "មិនយល់ស្របទេ"។ ដែលគួរឱ្យភ្ញាក់ផ្អើលចំពោះគាត់ គាត់គឺជាមនុស្សតែម្នាក់ ដែលរត់ទៅដើមឈើមួយនោះ! អ្នកដឹកនាំនិស្សិតផ្សេងទៀត ទាំងអស់សើច ហើយចង្អុលទៅគាត់ ដោយនិយាយថា "អូ! ជីស ឯងកំប្លែងលេងណាស់។ យើងទាំងអស់គ្នាដឹងថា ឯងមិនប្រាកដជាអញ្ចឹងនោះទេ"។ នៅវេលានោះ ជីស បាននិយាយថា គាត់ដឹងប្រាកដនូវអ្វីដែលគាត់ត្រូវតែធ្វើ ហើយគាត់បានប្រកាសយ៉ាងខ្លាំងថា--- "ខ្ញុំមិនកំប្លែងលេងនោះទេ។ ខ្ញុំពិតជាជឿដូច្នេះមែន!" មានការស្ងៀមស្ងាត់ដោយភាពភ្ញាក់ផ្អើលមួយ ហើយបន្ទាប់មកក្រុមបានបំបែកគ្នាទុកឱ្យ ជីស នៅឈរតែម្នាក់ឯងជិតដើមឈើ។ គាត់មានអារម្មណ៍វង្វេងវង្វាន់ ហើយមែនហើយ--- ចម្លែកទៀត។ ប៉ុន្តែគាត់មិនចម្លែកទេ។ គាត់ធ្វើត្រឹមត្រូវ។ ហើយគាត់មិននៅតែម្នាក់ឯងទេ។ នៅអំឡុងសប្ដាហ៍ មានអ្នកដឹកនាំនិស្សិតជាច្រើនបានមករកគាត់ដោយសម្ងាត់ ហើយបាននិយាយថា ពួកគេមានបំណងថាពួកគេបានដឹងនូវអ្វី ដែលគាត់បានដឹងតាំងពីមុន។ ក្រោយមក ជីស បាននិយាយថា "វាងាយស្រួលទេ ដោយសារខ្ញុំបានដឹងថាខ្ញុំជាតំណាងមិនមែនគ្រាន់តែឱ្យសកលវិទ្យាល័យប៉ុណ្ណោះទេ ប៉ុន្តែជាតំណាងឱ្យគ្រួសាររបស់ខ្ញុំ សាសនាចក្រ និងព្រះអង្គសង្គ្រោះ"។

ទីបន្ទាល់មួយដែលថាព្រះយេស៊ូវគ្រីស្ទ គឺជាព្រះអង្គសង្គ្រោះ និងជាព្រះប្រោសលោះ បានធ្វើឱ្យ ជីស រឹងមាំ ហើយរហ័សឆ្លើយតប។ អ្នកអាចទទួលបាននូវទំនុកចិត្តដូចគ្នានេះ នៅពេលអ្នកអធិស្ឋានជាប្រចាំថ្ងៃ ស្វែងរកចម្លើយ

នៅក្នុងបទគម្ពីររបស់អ្នក ហើយគោរពតាមបទបញ្ញត្តិទាំងឡាយ។ នៅពេលអ្នកស្វែងរកដោយស្មោះស្ម័គ្រដើម្បីទទួលបានទីបន្ទាល់មួយ ចំណេះដឹងនោះនឹងប្រទានមកតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដែលជួយអ្នកនៅក្នុងឧបសគ្គទាំងឡាយ សំណួរ និងការរស់នៅតាមបទដ្ឋានរបស់អ្នក។ ហើយវានឹងងាយស្រួលសំរាប់អ្នកផងដែរ ដើម្បីប្តេជ្ញាចិត្តឱ្យនៅខ្ជាប់ខ្ជួន និងឥតបែរចេញនៅគ្រប់ពេល និងគ្រប់សេចក្តី និងគ្រប់ទីកន្លែង។

ការខ្ជាប់ខ្ជួន និងឥតបែរចេញ មានន័យថាគោរពប្រណិបត្តិ។ មូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើនដែលអ្នកនៅលើផែនដីនេះ គឺដើម្បីបង្ហាញថា បើអ្នកនឹងអនុវត្តសិទ្ធិសេរីភាពរបស់អ្នក ហើយ "ប្រព្រឹត្តនូវអ្វីៗគ្រប់យ៉ាងដែលព្រះអម្ចាស់...នឹងបញ្ជា" ឬទេ ( អ័ប្រាហាំ 3:25 )។ នៅពេលអ្នករំលឹកសេចក្តីសញ្ញារបស់អ្នករាល់សប្តាហ៍ ដោយការទទួលទានសាក្រាម៉ង់ នោះអ្នកបានចុះសេចក្តីសញ្ញាថា អ្នកនឹងចងចាំព្រះអង្គសង្គ្រោះ ហើយរក្សាបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ជានិច្ច។

អំណោយទានដ៏មានតម្លៃនៃរូបកាយរបស់អ្នក អាចឱ្យអ្នកអនុវត្តនូវសិទ្ធិសេរីភាពរបស់អ្នក ហើយដាក់សេចក្តីជំនឿ និងការគោរពប្រណិបត្តិរបស់អ្នក មកជាសកម្មភាព។ តើអ្នកមានចាប់អារម្មណ៍ឬទេ ថាការវាយប្រហារទាំងអស់របស់សាតាំងគឺតំរង់មកលើរូបកាយរបស់អ្នក? រូបអាសគ្រាម ភាពមិនរមទម្យ ចាក់សាក់ ភាពអសីលធម៌ ការរំលោភបំពានខាងគ្រឿងញៀន និងការញៀន គឺជាការខិតខំទាំងអស់ដើម្បីទាញយកអំណោយទានដ៏មានតម្លៃនេះ។ នេះគឺជាអំណោយទានមួយដែលត្រូវបានបដិសេធសាតាំង។ ការគោរពប្រណិបត្តិចំពោះបទបញ្ញត្តិ និងបទដ្ឋានទាំងឡាយ អាចឱ្យអ្នករាល់គ្នាម្នាក់ៗនៅខ្ជាប់ខ្ជួន និងឥតបែរចេញ នៅក្នុងការការពារនូវអំណោយទានដ៏មានតម្លៃទាំងឡាយ នៃសិទ្ធិសេរី-ភាពរបស់អ្នក និងរូបកាយរបស់អ្នក។

ការខ្ជាប់ខ្ជួន និងឥតបែរចេញក៏មានន័យផងដែរថា អ្នកនៅបន្តឆ្ពោះទៅមុខដោយ "ភាពខ្ជាប់ខ្ជួនទៅលើព្រះគ្រីស្ទ" (នីហ្វៃទី 2 31:20 )។ ជាច្រើនឆ្នាំកន្លងទៅហើយ ខ្ញុំមានឱកាសដើម្បីរត់ប្រណាំងនៅទីក្រុងបូស្តុន ។ ខ្ញុំបានហ្វឹកហាត់យ៉ាងខ្លាំង ហើយមានអារម្មណ៍ថា ខ្ញុំបានត្រៀមខ្លួនហើយ ប៉ុន្តែនៅចម្ងាយផ្លូវម៉្កៅម៉ែលមានទួលជាច្រើន។ តំបន់ទាំងនោះហៅថាទួលដែលចោទបំផុត និងវែងបំផុត និងបាក់ទឹកចិត្ត។ នៅពេលខ្ញុំទៅដល់ចំនុចនោះ ខ្ញុំអស់កម្លាំងណាស់។ ទួលនោះវែង ហើយដោយសារខ្ញុំជាអ្នករត់ថ្មី ខ្ញុំបានធ្វើអ្វីមួយដែលអ្នករត់ប្រណាំង មានបទពិសោធន៍មិនធ្វើ--- ខ្ញុំបានចាប់ផ្តើមគិតផ្ទុយ។ រឿងនេះបានធ្វើឱ្យខ្ញុំបន្ថយល្បឿន ដូច្នេះខ្ញុំបានព្យាយាមគិតវិជ្ជមាន ហើយស្រមៃមើលនូវទីផ្តាច់ព្រាត់។ ប៉ុន្តែនៅពេលខ្ញុំធ្វើដូចនេះ រំពេចនោះខ្ញុំបានដឹងថាខ្ញុំនៅក្នុងទីក្រុងធំមួយ ដែលមានមនុស្សរាប់ពាន់ឈរតំរៀបជួរតាមផ្លូវ ហើយខ្ញុំមិនបានរៀបចំថាឱ្យស្វាមីរបស់ខ្ញុំជួបនៅកន្លែងណានៅពេលបញ្ចប់ការរត់ប្រណាំងទេ។ ខ្ញុំមានអារម្មណ៍ថាចាញ់ហើយ ហើយនៅតែឯង ខ្ញុំបានចាប់ផ្តើមយំ។ ខ្ញុំពាក់អាវយឺតក្រហមធំមួយ ដែលមានសរសេរថា *រដ្ឋយូថាហ៍* បានបោះពុម្ពនៅខាងមុខជាអក្សរធំលាត។ នៅពេអ្នកមើលបានឃើញថាខ្ញុំយំ ពួកគេស្រែកបន្តថា "បន្តទៅមុខទៀត យូថាហ៍" "កុំយំ យូថាហ៍" "អ្នកជិតដល់ទីហើយ យូថាហ៍"។ ប៉ុន្តែខ្ញុំដឹងថាមិនទាន់ដល់ទីទេ ខ្ញុំចាញ់ហើយ។ ខ្ញុំក៏ដឹងថាទោះបីជាខ្ញុំឈប់រត់ លែងប្រណាំង ខ្ញុំក៏នឹងនៅតែចាញ់ដែរ។

តើមាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា ធ្លាប់មានអារម្មណ៍ថា ដូចជាអ្នកកំពុងតែរត់ឡើងភ្នំដោយអស់សង្ឃឹម ទោះជាមានមនុស្សឈរនៅតាមតំរៀបជួរនៅតាមផ្លូវ តែអ្នកមានអារម្មណ៍ថានៅតែម្នាក់ឯងឬទេ? នោះហើយជាអ្វីដែលខ្ញុំធ្លាប់មានអារម្មណ៍ ដូច្នេះខ្ញុំបានធ្វើនូវអ្វីដែលអ្នកគ្រប់គ្នាធ្វើដែរ--- ខ្ញុំចាប់ផ្តើមអធិស្ឋាននៅទីនោះ នៅលើផ្លូវ

រត់ប្រណាំងនោះ។ ខ្ញុំបានប្រាប់ព្រះវរបិតាថា ខ្ញុំនៅឯកកោ ហើយថាខ្ញុំនៅលើទូលមួយ។ ខ្ញុំប្រាប់ទ្រង់ថាខ្ញុំបាក់ទឹកចិត្ត ហើយខ្ញុំខ្លាច ហើយមានអារម្មណ៍ថាចាញ់។ ខ្ញុំបានសុំជំនួយ និងកម្លាំងដើម្បីនៅខ្ជាប់ខ្ជួន ហើយបញ្ចប់ការប្រណាំង។ នៅពេលខ្ញុំបន្តរត់ ពាក្យទាំងនេះបានចូលមកក្នុងគំនិតរបស់ខ្ញុំ:

*"កុំខ្លាចអី ខ្ញុំនឹងនៅជាមួយកុំភ័យអីឡើយ*

*ព្រោះខ្ញុំជាព្រះអ្នក ហើយនឹងនៅតែយាងមកជួយ*

*ខ្ញុំនឹងចំរើនកម្លាំង ជួយគាំទ្រអ្នកឱ្យឈរ*

*នឹងលើកអ្នកដោយព្រះហស្តដ៏សុចរិត ដ៏អស្ចារ្យ"* (ទំនុកដំកើង # 6 "គ្រឹះដ៏មាំមួន")។

ចម្លើយដ៏ផ្អែមល្ហែមចំពោះការអធិស្ឋានរបស់ខ្ញុំនោះ បានផ្តល់កម្លាំងដល់ខ្ញុំឱ្យបន្តរហូតដល់ខ្ញុំបានឆ្លងកាត់ខ្សែផ្តាច់ព្រាត់។ ហើយយកឈ្នះភាពភ័យខ្លាចរបស់ខ្ញុំ ស្វាមីរបស់ខ្ញុំគឺនៅទីនោះ ហើយអ្វីៗទាំងអស់បានស្រួល។

ថ្ងៃនោះ ខ្ញុំមានបទពិសោធន៍ច្រើនជាការរត់ប្រណាំង។ ខ្ញុំបានរៀនមេរៀនសំខាន់ៗមួយចំនួន។ ដំបូងគេ --- កុំឱ្យពាក់អាវយឺតពណ៌ក្រហមដែលមានបោះពុម្ពពាក្យ *យូថាហ៍* ដែលបានបោះពុម្ពនៅលើនោះ។ ទីពីរ ខ្ញុំរៀនចេះថា មិនថាឡើយយើងត្រៀមខ្លួនល្អយ៉ាងណាទេ គឺមានទួលជាច្រើននៅលើផ្លូវនោះ។ ខ្ញុំរៀនថាមនុស្សដែលនៅអបអរឱ្យអ្នកតាមផ្លូវគឺមានសារៈសំខាន់ខ្លាំងណាស់។ ខ្ញុំបានរៀនម្តងទៀតថា ថ្ងៃនោះយើងមិននៅតែម្នាក់ឯងទេ។ ព្រះវរបិតាសួគ៌របស់យើងគឺជាមិនមែននៅត្រឹមតែការអធិស្ឋាននោះទេ ហើយព្រះវិញ្ញាណបរិសុទ្ធគឺនៅជិតល្មមដើម្បីឱ្យមនុស្សស្តាប់ឮការខ្សឹបរបស់ទ្រង់។

ខ្ញុំថ្លែងទីបន្ទាល់ថានៅពេលអ្នកឈរជាសាក្សីម្នាក់ គោរពតាមបទបញ្ញត្តិទាំងឡាយ ហើយបន្តជឿនទៅមុខដោយ "ខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ" អ្នកនឹងមិននៅតែម្នាក់ឯងទេ។ អ្នកអាចពឹងផ្អែកទៅលើព្រះចេស្តា នៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ។ ហើយខ្ញុំថ្លែងទីបន្ទាល់ថាការសង់នៅលើគ្រឹះរឹងមាំនេះ នឹងជួយអ្នកឱ្យប្រែក្លាយដូចជាទ្រង់--- នៅខ្ជាប់ខ្ជួន និងឥតបែរចេញ នៅគ្រប់ពេល គ្រប់សេចក្តី និងគ្រប់ទីកន្លែង។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។